| **សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ**<br>**១.ទុយោទឹកដើម្បីតភ្ជាប់ទៅទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី**<br>**២.ទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី និង ៣.សម្ភារនិងការតម្លើងប្រព័ន្ធផលិតទឹកសុទ្ធ**<br>**នៅសហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ អូរជាំ និង ៤.ទុយោតបណ្តាញទឹក**<br>**នៅសហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ តាតោកអូរក្រូច** | | |
|---|---|---|
| ខេត្ត៖ **បាត់ដំបង** | ស្រុក៖ សំឡូត | ឃុំ សង្កាត់៖ កំពង់ល្ពៅ និងតាតោក |

- អង្គការម្លប់បៃតង (MB) បាននឹងកំពុងអនុវត្តគម្រោងដោយបានការគាំទ្រថវិកាពីកម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក នៃគម្រោង “ការធ្វើឲ្យមាននិរន្តភាពបរិស្ថាន និងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍” **KHM/SGP/ OP7/YI/CORE/BD/2021/01** ក្នុងភូមិអូរជាំលើ ឃុំកំពង់ល្ពៅ និងភូមិអូរក្រូច ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង ព្រមទាំងមានកិច្ចសហការជាមួយមន្ទីរបរិស្ថាន មន្ទីរទេសចរណ៍ ខេត្តបាត់ដំបង និងអាជ្ញាធរមូលដ្ឋានបានកំពុងអនុវត្តនូវកម្មវិធីរបស់ខ្លួន។

**១. ការពិពណ៌នាអំពីលទ្ធផលនៃកិច្ចសន្យាការផ្គត់ផ្គង់ ទុយោទឹកដើម្បីតភ្ជាប់ទៅទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី ទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី និង សម្ភារនិងការតម្លើងប្រព័ន្ធផលិតទឹកសុទ្ធ នៅសហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ អូរជាំ និង ទុយោតបណ្តាញទឹកនៅសហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ តាតោកអូរក្រូច៖**

១.១. **ការផ្គត់ផ្គង់ទុយោទឹកដើម្បីតភ្ជាប់ទៅទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី៖** សម្រាប់រៀបចំតប្រព័ន្ធបណ្តាញទុយោទឹក (ទុយោខ្មៅ) ប្រភេទ HDPE Pipe កម្រាស់ PN8 ទំហំ OD125mm មានប្រវែង ៩៦ម៉ែត្រ (ចំនួន ៨ដើម ដែលក្នុង១ដើមប្រវែង ១២ម) និង កម្រាស់ PN8 ទំហំ110mm មានប្រវែង ៦៤៨ម៉ែត្រ (ចំនួន ៥៤ដើម ដែលក្នុង១ដើមប្រវែង ១២ម) ដើម្បីភ្ជាប់ទៅទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី នៅសហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ អូរជាំ និង**ការផ្គត់ផ្គង់ប្រព័ន្ធទុយោតបណ្តាញទឹក** (ទុយោខ្មៅ) ប្រភេទ HDPE Pipe កម្រាស់ PN8 ទំហំ OD 90mm មានប្រវែង ២០០ម៉ែត្រ ទំហំ 63mm មានប្រវែង ២០០ម៉ែត្រ ទំហំ 50mm មានប្រវែង ៤,៦០០ម៉ែត្រ និងគ្រឿងបង្គុំមួយកំផ្លេ (ព័ត៌មានលំអិតនឹងមានបង្ហាញជូនក្នុងឯកសារដេញថ្លៃ ឧបសម្ព័ន្ធ១ និង២) ដើម្បីតភ្ជាប់ពីប្រភពទឹកធ្លាក់តាតោកអូរក្រូច នៅសហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ តាតោកអូរក្រូច។

១.២. **ការផ្គត់ផ្គង់ទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី៖ ជាប្រភេទទួរប៊ីនវារីអគ្គីសនី (Hydraulic Generator)៖** សម្រាប់ផលិតអគ្គីសនីដែលមានកម្លាំង ១៥Kwh ដែលមានខ្នាតទុយោចូលចន្លោះ ១១០-១៦០ ម.ម (ព័ត៌មានលំអិតនឹងមានបង្ហាញជូនក្នុងឯកសារដេញថ្លៃ ឧបសម្ព័ន្ធ៣)។

១.៣. **សម្ភារនិងការតម្លើងប្រព័ន្ធផលិតទឹកសុទ្ធ៖** នៅសហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ អូរជាំ ដែលអាចផលិតទឹកបានចំណុះ 250លីត្រ/ម៉ោង តាមបច្ចេកទេស សម្អាតទឹក RO System Ozone និងប្រព័ន្ធសម្លាប់មេរោគ UV ។ បញ្ជាក់៖ អ្នកទទួលការទទួលខុសត្រូវក្នុងការយកទឹកមុនចូលប្រព័ន្ធផលិតទឹកសុទ្ធ (១លើក) និងទឹកសុទ្ធ (១លើក) ទៅត្រួតពិនិត្យគុណភាព នៅមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា (ព័ត៌មានលំអិតនឹងមានបង្ហាញ

<table>
<tr><td colspan="2">ជូនក្នុងឯកសារដេញថ្លៃ ឧបសម្ព័ន្ធ៤)។<br><br>សម្គាល់៖<br><br>- រយៈពេលនៃការផ្គត់ផ្គង់ លើចំណុច១.១ ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២ ដឹកដល់តំបន់គោលដៅសហគមន៍ទាំងពីរ។<br><br>- រយៈពេលនៃការផ្គត់ផ្គង់ លើចំណុច១.២ ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ដឹកដល់តំបន់គោលដៅសហគមន៍អូរដាំ។<br><br>- រយៈពេលនៃការផ្គត់ផ្គង់ លើចំណុច១.៣ មានរយៈពេល ៦០ថ្ងៃ (ដឹកដល់តំបន់គោលដៅ និងតម្លើងប្រព័ន្ធផលិតទឹកបរិសុទ្ធ នៅសហគមន៍អូរដាំ) បន្ទាប់ពីបញ្ចប់ការសាងសង់តម្លើងទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី ដំណើការផ្តល់ភ្លើងអគ្គីសនីសមស្រប។</td></tr>
<tr><td>តម្លៃប៉ាន់ស្មានសរុប<br>(គិតរួមទាំងថ្លៃដឹកជញ្ជូនដល់ទីតាំងសហគមន៍)</td><td>- ការផ្គត់ផ្គង់ទុយោទឹកដើម្បីតភ្ជាប់ទៅទួរប៊ីនសម្រាប់បង្កើតវារី អគ្គីសនី តម្លៃ ៤,១៣០.០០ដុល្លា<br>- ការផ្គត់ផ្គង់ប្រព័ន្ធទុយោតបណ្ដាញទឹក តម្លៃ ៧,១០០.០០ដុល្លា<br>- ការផ្គត់ផ្គង់ទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី តម្លៃ ៥,៨០០.០០ដុល្លា<br>- សម្ភារនិងការតម្លើងប្រព័ន្ធផលិតទឹកសុទ្ធ តម្លៃ ៩,០០០.០០ដុល្លា</td></tr>
<tr><td>អ្នកដែលអាចដេញថ្លៃ</td><td></td></tr>
<tr><td>ចំនួនប្រាក់កក់ធានាការដេញថ្លៃ (២%)</td><td>- ការផ្គត់ផ្គង់ប្រព័ន្ធទុយោទឹកសរុប ២២៥.០០ (ពីររយម្ភៃប្រាំដុល្លា)<br>- ការផ្គត់ផ្គង់ទួរប៊ីនសម្រាប់បង្កើតវារីអគ្គីសនី ១១៦.០០ (មួយរយដប់ប្រាំមួយដុល្លា)<br>- សម្ភារនិងការតម្លើងប្រព័ន្ធផលិតទឹកសុទ្ធសរុប ១៨០.០០ (មួយរយប៉ែតសិបដុល្លា)</td></tr>
<tr><td>ឈ្មោះធនាគារពាណិជ្ជដែលត្រូវតម្កល់ប្រាក់កក់</td><td>ធនាគារពាណិជ្ជណាមួយ ក្នុងខេត្តបាត់ដំបង ឬនៅរាជធានីភ្នំពេញ</td></tr>
<tr><td>រយៈពេលសុពលភាពនៃសំណើដេញថ្លៃ</td><td>ចំនួន ៤៥ (សែសិបប្រាំ) ថ្ងៃ ចាប់ពីថ្ងៃប្រជុំបើកសំណើដេញថ្លៃ</td></tr>
<tr><td>ទីកន្លែងដែលអាចទទួលឯកសារដេញថ្លៃ</td><td>- សហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ អូរដាំ (០៨៦.៦០.៦០.៨៣, ០៧៧.៥៥.១១.៥៨)<br>- សាលាឃុំតាតោក (០៩២.១៣៧.៦៩៧)<br>- សាលាឃុំកំពង់ល្ពៅ (០៨៧.៦១១.២៨៨)<br>ឯកសារសំណើដាក់ដេញថ្លៃត្រូវដាក់នៅក្នុងស្រោម</td></tr>
</table>

| | |
|---|---|
| | សំបុត្របិទជិតផ្ញើមកកាន់ទីតាំងទទួលពាក្យណាមួយខាងលើ។ |
| កាលបរិច្ឆេទទទួលពាក្យ និងការដេញថ្លៃ | ជូនដំណឹង និងទទួលសំណុំឯកសារដេញថ្លៃ រៀងរាល់ថ្ងៃធ្វើការ (ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ)៖<br>ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២<br>- ព្រឹក ពីម៉ោង ៨:០០នាទី ដល់ម៉ោង ១២:០០នាទី<br>- រសៀល ពីម៉ោង ២:០០នាទី ដល់ម៉ោង ៥:៣០នាទី<br>និង ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២<br>- ពីម៉ោង ៨:០០នាទី ដល់ម៉ោង ៨:៣០នាទី |
| ទីកន្លែងនៃការប្រជុំបើកសំណើដេញថ្លៃ | សហគមន៍តំបន់ការពារធម្មជាតិ-អេកូទេសចរណ៍ អូរជាំ |
| កាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ | ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២២ |
| • ពេលវេលាបើកសំណើដេញថ្លៃ | ម៉ោង ០៨:៣០នាទីព្រឹក |

**កំណត់សម្គាល់៖**

- អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយសំណើដេញថ្លៃរបស់ខ្លួននូវប័ណ្ណពន្ធប៉ាតង់ដែលមានសុពលភាព ឬបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធប៉ាតង់ចំនួន ០១ច្បាប់ (ច្បាប់ថតចម្លងដែលមាននីត្យានុកូលកម្ម) បើពុំនោះសោតទេ សំណើដេញថ្លៃពុំមានសុពលភាពឡើយ ហើយប្រាក់ធានាការដេញថ្លៃនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិកាគម្រោងរបស់អង្គការម្លប់បៃតង។
- អ្នកដេញថ្លៃឈ្នះក្នុងការដេញថ្លៃនឹងត្រូវតម្កល់ប្រាក់កក់ធានាការអនុវត្តចំនួន ១០% នៃតម្លៃកិច្ចសន្យា។ ប្រាក់កក់នេះមានសុពលភាពរហូតដល់ចប់រយៈពេលថែទាំ/ផលិត និងផ្គត់ផ្គង់ លទ្ធផលកិច្ចសន្យា ឬរយៈពេលធានាគុណភាពផលិតផល។
- អ្នកទទួលការ ត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការដឹកជញ្ជូនថែទាំលទ្ធផលកិច្ចសន្យា និងជួសជុលនូវរាល់ការខូចខាតទាំងអស់នៅក្នុងអំឡុងពេល៦ខែ បន្ទាប់ពីការផ្គត់ផ្គង់ និងតម្លើងរួចជាស្ថាពរ នៃការអនុវត្តគម្រោង។
- អ្នកដេញថ្លៃត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ព័ន្ធនិងការក្លែងបន្លំ ឬអំពើពុករលួយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នា ឬពាក់ព័ន្ធក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះ និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងទេ ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិកាគម្រោងរបស់អង្គការម្លប់បៃតង ។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២២

**ប្រធានគណកម្មការលទ្ធកម្ម**

**អោម សុផាណា**

សម្រាប់ព័ត៌មានលំអិត ព្រមទាំងឯកសារដេញថ្លៃ សូមទាក់ទងក្រុមការងារគម្រោងអង្គការម្លប់បៃតង៖ ផ្ទះលេខ១៩៤ ផ្លូវ៣៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ៖ ០៨៦.៦០.៦០.៨៣

០១២.៤១៣.៨៥៧ និង

០៧៨.៥៥៥.២០៩